ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះ ហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

# អនុក្រឹត្យលេខ ២៩ អនក្រ.បក

## ស្តីពី

## ថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ បណ្ណស្នាក់នៅរយៈពេលខ្លី និង បណ្ណស្នាក់នៅអចិន្ត្រៃយ៍ សំរាប់ជនបរទេសអន្តោប្រវេសន្ត

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិ ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ

តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១** : អាករលើលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ឯកសារធ្វើដំណើរ ចំនួនបីសែនរៀល ( ៣០០.០០០៛,០០ ) ។

ខ-លិខិតបើកផ្លូវ ចំនួនប្រាំម៉ឺនរៀល ( ៥០.០០០៛,០០ ) ។

**មាត្រា ២** : អាករលើការពន្យារលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ការពន្យាពេលឯកសារធ្វើដំណើ ចំនួនប្រាំម៉ឺនរៀល ( ៥០.០០០៛,០០ )

ខ-ការពន្យារពេលលិខិតបើកផ្លូវ ចំនួនបីម៉ឺនប្រាំពីរពាន់ប្រាំរយរៀល (៣៧.៥០០៛,០០) ។

**មាត្រា ៣** : កុមារទាំងពីរភេទមានអាយុ ១២ ឆ្នាំ ចុះ ដែលរួមដំណើរជាមួយឪពុក ម្តាយ ឬ អាណាព្យាបាល ត្រូវបានរួចអាករ ។

**មាត្រា ៤** : អាករលើប័ណ្ណស្នាក់នៅត្រូវកំណត់ដូចខាងក្រោម :

ក-ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ( មានសុពលភាព ១ ឆ្នាំជាអតិបរិមា ) ចំនួនពីរសែន ប្រាំម៉ឺនរៀល ( ២៥០.០០០៛,០០ ) ។

ខ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ( មានសុពលភាព ២ ឆ្នាំ ) ចំនួនប្រាំសែនរៀល ( ៥០០.០០០៛,០០ ) ។

គ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតាចំនួនប្រាំសែនរៀល(៥០០.០០០៛,០០)។

**មាត្រា ៥** : ថ្លៃអាករលើការពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ត្រូវកំណត់ចំនួនប្រាំសែនរៀល ( ៥០០.០០០៛,០០ ) ។

**មាត្រា ៦** : ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។
បែបបទ នៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ៧** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៣០ អនក្រ.បក

## ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២